CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៣ ខែកក្កដាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# លោកអភិបាលរដ្ឋ Newsom បានប្រកាសបិទកន្លែងបន្ថែមទៀត ដើម្បីបន្ថយការរាលដាលនៃជំងឺ COVID-១៩

*ប្រតិបត្តិការនៅតាមផ្ទៃកខាងក្នុងនៃវិស័យជាច្រើននៅឡុងប៊ិចនឹងរងផលប៉ះពាល់*

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - អភិបាលរដ្ឋ Newsom និងរដ្ឋកាលីហ្វ័រញ៉ាបានប្រកាសបិទបន្ថែមទៀតនូវប្រតិបត្តិការតាមផ្ទៃកខាងក្នុងនៅតាមខោនធីជាច្រើនរួមទាំងខោនធីទាំងអស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាភាគខាងត្បូង។ ទីក្រុងឡុងប៊ិចនឹងចេញនូវបទបញ្ជាសុខភាពថ្មីដែលតម្រូវឱ្យបិទប្រតិបត្តិការផ្ទៃកខាងក្នុងនៃទីតាំងបន្ថែមដែលបណ្តាលឲ្យគ្រួសារផ្សេងគ្នាជួបជុំនៅតាមកន្លែងដែលមិនអាចអនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាបានឬពាក់ម៉ាសដើម្បីតម្រឹមជាមួយនឹងបទបញ្ជារបស់រដ្ឋ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "លោកអភិបាលរដ្ឋ Newsom កំពុងតែធ្វើការបិទបន្ថែមនៅទូទាំងរដ្ឋដើម្បីការពារដល់សុខភាពសាធារណៈហើយយើងគាំទ្រការសម្រេចចិត្តរបស់គាត់។ នេះជាពេលវេលាដ៏លំបាកសម្រាប់ម្ចាស់អាជីវកម្មខ្នាតតូចនិងអ្នកធ្វើការប៉ុន្តែចំនួននៃអ្នកចូលស្នាក់ព្យាបាលនៅមន្ទីរពេទ្យកំពុងតែកើនឡើងហើយយើងត្រូវផ្តោតលើចំណុះមន្ទីរពេទ្យ។"

ការបិទបន្ថែមនៃប្រតិបត្តិការផ្ទៃកខាងក្នុងនៃទីតាំងផ្សេងៗធ្វើឱ្យប៉ះពាល់ដល់ស្រុកសាមសិបដែលមាននៅក្នុងបញ្ជីតាមដានខោនធីក្នុងរយៈពេលបីថ្ងៃជាប់ៗគ្នារួមមានខោនធី Los Angeles ខោនធី Orange ខោនធី Riverside ខោនធី San Bernardino និងខោនធី San Diego។ អាជីវកម្មខាងក្រោមអាចធ្វើ

ប្រតិបត្តិការខាងក្រៅដោយអនុលោមទៅតាមបទបញ្ជាសុខភាពរបស់ទីក្រុងឡុងប៊ិចនិងទទួលបានការអនុញ្ញាតដែលចេញដោយក្រុងក្នុងការ  អនុវត្តសកម្មភាពទាំងនេះ៖

- សេវាកម្មថែសម្ផស្សរួមមានហាងធ្វើក្រចក ហាងធ្វើឱ្យស្បែកកាន់តែខ្មៅ អ្នកជំនាញខាងថែរក្សាស្បែក ហាងថែស្បែក និងហាងគ្រឿងសំអាង ព្រមទាំងអ្នកជំនាញសិល្បៈរាងកាយរួមមានហាងសាក់លើស្បែក ការសាក់ចិញ្ចើម និងការសាក់គ្រឿងសំអាងនៅលើផ្ទៃមុខ និងហាងចោះក៏ដូចជាការព្យាបាលដោយការធ្វើសរសៃ (ក្នុងកន្លែងដែលមិនមែនជាមន្ទីរពេទ្យ)
- កន្លែងហាត់ប្រាណ
- ហាងកាត់និងអ៊ុតសក់
- ពិធីសាសនានិងពិធីវប្បធម៌ផ្សេងៗ
- ការធ្វើបាតុកម្មតវ៉ាផ្នែកនយោបាយ

ផ្នែកខាងក្នុងនៃផ្សារទំនើបត្រូវតែបិទទ្វារជាសាធារណៈលើកលែងតែហាងនិងតូបលក់ដែលអាចចូលបានពីក្រៅផ្សារទំនើប។ ហាងលក់ទំនិញនិងតូបលក់ដែលមានទីតាំងនៅផ្នែកខាងក្នុងនៃផ្សារទំនើបអាចដំណើរការសម្រាប់ការមកយកនៅតាមដងផ្លូវការមកយកនៅតាមមាត់ទ្វារឬការដឹកជញ្ជូនផ្សេងៗតែប៉ុណ្ណោះ។ ផ្សារទំនើបដែលមានទីតាំងនៅខាងក្រៅផ្សារទំនើបធំៗដែលលក់ដោយផ្ទាល់ដល់សាធារណៈនៅខាងក្រៅនិងផ្សារមេឃអាចបន្តបើកបាន។

អាជីវកម្មដែលតម្រូវឱ្យនិយោជិកធ្វើការពីការិយាល័យដែលត្រូវបានកំណត់ថាជាអាជីវកម្មមិនចាំបាច់ឬមិនមែនជាប្រតិបត្តិការផ្នែកថែទាំសុខភាពឬហេដ្ឋារចនាសម្ព័ន្ធចាំបាច់អាចនឹងធ្វើការបានតាមរយៈទូរគមនាគមន៍និងសម្រាប់តែប្រតិបត្តិការមូលដ្ឋានអប្បបរមាប៉ុណ្ណោះ។

ការបិទជាចាំបាច់នឹងចូលជាធរមាននៅយប់នេះគឺបន្ទាប់ពីពាក់កណ្តាលអធ្រាត្រ (នៅម៉ោង ១២:០១ នាទីថ្ងៃទី ១៤ ខែកក្កដាឆ្នាំ ២០២០)។ បទបញ្ជាសុខភាពរបស់ទីក្រុងឡុងប៊ិចដែលត្រូវបានកែប្រែដែលមានព័ត៌មានលំអិតស្តីពីការបិទទាំងនេះនឹងចេញផ្សាយនៅថ្ងៃនេះនៅលើគេហទំព័រ longbeach.gov/COVID19។

យោងតាមគោលការណ៍ណែនាំរបស់រដ្ឋសម្រាប់ដំណើរការបើកឡើងវិញឡុងប៊ិចដែលជាទីក្រុងដែលមានមន្ទីរសុខាភិបាលផ្ទាល់ខ្លួនត្រូវបានរាប់បញ្ចូលជាមួយនឹងខោនធី Los Angeles។ ទោះបីជារដ្ឋពិចារណាលើឡុងប៊ិចដោយឡែកក៏ទិន្នន័យរបស់ឡុងប៊ិចនៅតែធ្វើឲ្យទីក្រុងនេះស្ថិតក្នុងបញ្ជីការបិទជាចាំបាច់ដដែល។

បទបញ្ជានេះតម្រូវឱ្យមានការបន្តបិទផ្នែកខាងក្នុងនៃភោជនីយដ្ឋាន សារមន្ទីរ សួនច្បាររុក្ខសាស្ត្រ និងអាងចិញ្ចឹមត្រីក៏ដូចជាការបន្តបិទបារ៍និងទីតាំងស្រដៀងគ្នាដែលមិនមានលិខិតអនុញ្ញាតសម្រាប់ភោជនីយដ្ឋានដែលចេញដោយទីក្រុង។ ការបិទជាចាំបាច់ទាំងនេះបានចូលជាធរមានរួចហើយ។

ដោយសារតែភាពអសមត្ថភាពក្នុងការ  អនុវត្តរាងកាយឱ្យនៅឃ្លាតឆ្ងាយពីគ្នាអាងងូតទឹកក្តៅសូណានិងបន្ទប់ចំហាយទឹកដែលមានទីតាំងនៅក្នុងកន្លែងរួមនិងនៅឯលំនៅដ្ឋានពហុគ្រួសារត្រូវបានតម្រូវឱ្យបិទ។

ករណីឆ្លងជំងឺ COVID-19 ឥឡូវមានចំនួន 5,616 អ្នកនៅឡុងប៊ិចហើយមនុស្ស 149 អ្នកបានស្លាប់ដោយសារវីរុសនេះ។ ប្រជាជនចំនួន ៩៧ អ្នកកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យដែលជាអត្រាខ្ពស់បំផុតសម្រាប់ទីក្រុងហើយអត្រាវិជ្ជមានគឺ 15.1%។ (អត្រាវិជ្ជមានគឺភាគរយនៃមនុស្សដែលបានទទួលលទ្ធផលតេស្តវិជ្ជមានចំពោះជំងឺឆ្លង។)

ម្ចាស់អាជីវកម្មដែលមានសំណួរទាក់ទងនឹងការបិទជាចាំបាច់នេះអាចទូរស័ព្ទទៅខ្សែពត៌មានអាជីវកម្មរបស់ទីក្រុងឡុងប៊ិចចន្លោះម៉ោង ៩ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រនៅលេខ 562.570.4BIZ។ ពលរដ្ឋដែលមានសំណួរអាចទូរស័ព្ទមកខ្សែរព័ត៌មានរបស់ទីក្រុងនៅចន្លោះម៉ោង ៩ ព្រឹកដល់ម៉ោង ៥ ល្ងាចពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រនៅលេខ 562.570.INFO។

សកម្មភាពនេះត្រូវបានបង្កើតឡើងដោយមន្ត្រីសុខាភិបាលទីក្រុងគឺវេជ្ជបណ្ឌិត Anissa Davis និងយោងទៅតាមអំណាចបន្ទាន់ (Emergency Powers) ដែលផ្តល់ទៅឱ្យអ្នកគ្រប់គ្រងក្រុងតាមរយៈការប្រកាសអាសន្នក្នុងតំបន់ (Proclamation of Local Emergency)។ សកម្មភាពនេះនឹងមានប្រសិទ្ធភាពនៅថ្ងៃទី 14 ខែកក្កដាឆ្នាំ 2020 បន្ទាប់ពីពាក់កណ្តាលអធ្រាត្រនៅម៉ោង 12:01 ព្រឹកហើយនឹងបន្តរហូតដល់ត្រូវបានពង្រីកដកហូតឬកែប្រែជាលាយលក្ខណ៍អក្សរដោយមន្ត្រីសុខាភិបាល។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #